**UNIVERSITY OF CALIFORNIA, SAN FRANCISCO**

# កម្រងសិទ្ធិឯកត្តជន

# របស់អ្នកដែលត្រូវធ្វើពិសោធន៍

សិទ្ធិខាងក្រោមគឺជាសិទ្ធិនៃបុគ្គលគ្រប់រូបដែលត្រូវបានស្នើសុំឱ្យចូលរួមក្នុងការសិក្សាស្រាវជ្រាវ។ ក្នុងនាមជាអ្នកដែលត្រូវធ្វើពិសោធន៍ អ្នកមានសិទ្ធិដូចខាងក្រោមៈ

1) ទទួលដំណឹងអំពីអ្វីដែលការសិក្សានេះកំពុងព្យាយាមស្វែងយល់,
2) ទទួលដំណឹងអំពីអ្វីដែលនឹងកើតមានចំពោះអ្នក ហើយថាតើនិតិវិធី ឱសថ ឬឧបករណ៍ទាំងឡាយខុសគ្នាពីអ្វីដែលនឹងប្រើប្រាស់ក្នុងការអនុវត្តស្តង់ដារឬយ៉ាងណា,
3) ទទួលដំណឹងអំពីផលប៉ះពាល់ ឬហានិភ័យសំខាន់ៗ ឬ/និង ញឹកញាប់ ឬភាពមិនស្រណុកស្រួលនៃអ្វីដែលនឹងកើតមានចំពោះអ្នកសម្រាប់គោលបំណងសិក្សា,
4) ទទួលដំណឹង ថាតើអ្នកអាចនឹងទទួលបានអត្ថប្រយោជន៍សម្រាប់ការចូលរួមនេះឬយ៉ាងណា ហើយ ប្រសិនបើដូច្នេះមែន តើអ្វីដែលអាចជាអត្ថប្រយោជន៍,
5) ទទួលដំណឹងអំពីជម្រើសផ្សេងៗទៀតដែលអ្នកមាន និងអំពីសភាពដែលវាអាចនឹងប្រសើរជាង ឬអាក្រក់ជាងការចូលរួមក្នុងការសិក្សា,
6) ទទួលបានការអនុញ្ញាតឱ្យសួរសំណួរទាំងឡាយដែលទាក់ទងនឹងការសិក្សាទាំងមុនពេលឯកភាពចូលរួម និងអំឡុងពេលនៃដំណើរការសិក្សា,
7) ទទួលដំណឹងអំពីប្រភេទនៃការព្យាបាលវេជ្ជសាស្ត្រដែលមាន ប្រសិនបើមានបញ្ហាណាមួយកើតឡើង,
8) បដិសេធការចូលរួមទាំងស្រុង ឬផ្លាស់ប្តូរចិត្តក្នុងការចូលរួមការសិក្សា បន្ទាប់ពីការសិក្សាបានចាប់ផ្តើម។ ការសម្រេចចិត្តនេះនឹងមិនប៉ះពាល់ដល់សិទ្ធិរបស់អ្នកដើម្បីទទួលបានការថែទាំដែលអ្នកនឹងទទួលបាន ប្រសិនបើអ្នកមិនបានចូលរួមក្នុងការសិក្សាឡើយ,
9) ទទួលបានច្បាប់ថតចម្លងនៃទម្រង់បែបបែបផ្តល់ការអនុញ្ញាតដែលមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខា,
10) មិនរងសម្ពាធនៅពេលពិចារណាថាតើអ្នកចង់ឯកភាពចូលរួមក្នុងការសិក្សាឬយ៉ាងណា។

គ្រូពេទ្យសិក្សារបស់អ្នកនឹងប្រាប់អ្នកប្រសិនបើការសិក្សាស្រាវជ្រាវត្រូវបានគ្រប់គ្រងដោយរដ្ឋបាលចំណីអាហារ និងឱសថ (Food and Drug Administration, FDA) ។ ប្រសិនបើការសិក្សានេះត្រូវបានគ្រប់គ្រងដោយ FDA, នៅក្រោមច្បាប់ Federal Food, Drug, និង Cosmetic Act (FD&C Act), នោះ FDA អាចនឹងធ្វើការពិនិត្យ និងថតចម្លងកំណត់ត្រាទាំងអស់ដែលទាក់ទងនឹងការចូលរួមរបស់អ្នកនៅក្នុងការសិក្សានេះ។

ប្រសិនបើអ្នកមានសំណួរផ្សេងទៀត អ្នកគួរសួរអ្នកសិក្សាស្រាវជ្រាវ ឬជំនួយការសិក្សាស្រាវជ្រាវ។ បន្ថែមពីនេះ អ្នកអាចទាក់ទងក្រុមប្រឹក្សាត្រួតពិនិត្យស្ថាប័ន (Institutional Review Board, IRB), ដែលមានតួនាទីផ្តល់ការការពារដល់អ្នកចូលរួមនៅក្នុងគម្រោងនៃការសិក្សាស្រាវជ្រាវ។ អ្នកអាចទាក់ទងការិយាល័យ IRB ដោយទូរសព្ទទៅលេខ៖ (415) 476-1814 ពីម៉ោង 8:00 ព្រឹក ដល់ម៉ោង 5:00 ល្ងាច ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ឬដោយសរសេរទៅកាន់កម្មវិធី UCSF Human Research Protection Program, Box 1288, 490 Illinois Street, Floor 6, San Francisco, CA 94143 ឬដោយអ៊ីមែលតាមរយៈ irb@ucsf.edu ។

ទូរសព្ទទៅលេខ (415) 476-1814 ឬអ៊ីមែល irb@ucsf.edu សម្រាប់ព័ត៌មានអំពីការបកប្រែ។